## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : ម្រុំ

ឈ្មោះវិទ្យាសាស្ត្រ : *Moringa oleifera* Lam

គ្រួសារ : Moringaceae

ចំណាត់ថ្នាក់ជាតិ : ឈើក្រៅលំដាប់ថ្នាក់

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

ដើមម្រុំមានប្រភពកំណើតនៅប្រទេសអេត្យូពី នៅភាគខាងជើងនៃប្រទេសកេនយ៉ា នៅភាគខាងជើងនៃប្រទេសឥណ្ឌា និងប្រទេសអារ៉ាប៊ីសាអូឌីត ក្នុងតំបន់ជុំវិញ ភ្នំហេមពាន្ត។ ប្រភេទនេះ ត្រូវបានរកឃើញនៅក្នុងប្រទេស សូដង់ អេហ្ស៊ីប អារ៉ាប់ ណាមីប៊ី និងអង់ហ្គោឡា ហើយត្រូវបានបែងចែកសាយភាយទៅស្ទើរគ្រប់ប្រទេស និងត្រូវបានដាំពាសពេញទូទាំងតំបន់អាស៊ីភាគអគ្នេយ៍។ ម្រុំជាដើមឈើដែលលូតលាស់រហ័ស ធន់នឹងភាពរាំងស្ងួត ខ្យល់ និងអាកាសធាតុត្រជាក់ខ្លាំង ហើយជ្រុះស្លឹកក្នុងមួយឆ្នាំម្តង។ ម្រុំជាដើមឈើចូលចិត្តដុះនៅលើដីល្បាយខ្សាច់ និងត្រូវពន្លឺថ្ងៃជាងនៅក្នុងម្លប់ ដូចជាដាំធ្វើព្រំប្រទល់ ធ្វើជារបងនៃវាលស្រែ ឬកសិដ្ឋាន។ ដើមម្រុំធន់ទៅនឹងភ្លើង ហើយអាចដុះលូតលាស់ឡើងវិញបានយ៉ាងល្អ បន្ទាប់ពីការកាត់ចុងមែក។ ប្រភេទនេះអាចដុះនៅរយៈកំពស់ចន្លោះ ០-១៤០០ម កំពស់ទឹកភ្លៀងប្រចាំឆ្នាំពី ៧៥០-២៥០០ម.ម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំពី ២៥-២៧ អង្សាសេ និងសីតុណ្ហភាពអតិបរមានៃខែ ក្តៅបំផុតពី ៣២-៤០ អង្សាសេ។ ម្រុំដុះនៅលើដីដែលមាន pH = ៥,៥-៧,៥ និង អាចដុះនៅលើដីដែលមិនសូវមានជីជាតិ និងដុះល្អបំផុតនៅលើដីល្បប់។

## ៣- ការប្រើប្រាស់

ម្រុំជាប្រភេទដើមឈើដែលមានប្រយោជន៍ច្រើនយ៉ាង មានសក្តានុពលខ្ពស់សំរាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។ ស្លឹក និងមែកតូចៗរបស់វាមានជាតិប្រូតេអ៊ីនខ្ពស់ ហើយត្រូវបានប្រើប្រាស់ពាសពេញអាហ្វ្រិកខាងត្បូង ក៏ដូចជាតំបន់ខ្លះនៃទ្វីបអាស៊ី ដោយធ្វើជាបន្លែ (ទឹកជ្រលក់ ស្លស្រឡក់ សម្លកកូរ)។ ស្លឹក និងមែកតូចៗក៏ជាចំណីអាហាររបស់ត្រីកាប ប្រភេទត្រីផ្សេងៗទៀត និងជាចំណីគោ ក្របី ពពែ ចៀមផងដែរ។ ស្លឹកដែលបុករួចត្រូវបានប្រើប្រាស់សំរាប់ដុសជូតសំអាតសំភារៈប្រើប្រាស់ចំអិនអាហារ និងសំអាតជញ្ជាំង។ ផ្លែខ្ចីអាចបរិភោគបាន ប្រើជាបន្លែស្ងោរ ធ្វើជ្រក់ ឬក៏តិណទេស។ ស្លឹក ត្រួយ ផ្លែ ក្រៅពីអាចធ្វើជាអាហារប្រចាំថ្ងៃរបស់មនុស្ស អាចការពារ ឬព្យាបាលបញ្ហាកង្វះ អាហាររូបត្ថម្ភទៀតផង ផ្លែខ្ចីសំរាប់បរិភោគ គ្រាប់ស្ងួតអាចហូបបានដូចសណ្តែកដី។ ឈើម្រុំអាចផ្សំជាថ្នាំជ្រលក់ពណ៌ខៀវ និងធ្វើជាអុសដុត។ សាច់ឈើអាចធ្វើក្រដាសសំរាប់បោះពុម្ពកាសែត ឬក្រដាសសរសេរ ហើយប្រើសំរាប់ធ្វើពោង ធ្វើប្រដាប់ក្មេងលេង និងសំរាប់ឧស្សាហកម្មតម្បាញ។ សំបកឈើម្រុំអាចវាយឱ្យទក់ចេញជាសរសៃសំរាប់ធ្វើជាខ្សែសរសៃអំបោះ ឬកន្ទេលក្រាល។ កាកគ្រាប់ម្រុំដែលចំរាញ់យកប្រេងរួច មិនអាចប្រើប្រាស់ធ្វើជាអាហាររបស់សត្វបានទេ ប៉ុន្តែអាចប្រើប្រាស់ជាជីសំរាប់ដាក់ដំណាំបាន។ គ្រាប់ដែលបុករួច អាចធ្វើអោយទឹកឃ្មុំឡើងថ្លាល្អ ហើយអាចប្រើសំរាប់ធ្វើឱ្យទឹកអំពៅឡើងថ្លា និងជាពិសេស នៅតាមសហគមន៍តាមជនបទ ត្រូវបានប្រើប្រាស់យ៉ាងសក្តិសិទ្ធ ព្រមទាំងមានតំលៃទាបសំរាប់កែប្រែ និងសំអាតភាពល្អក់កករនៃទឹកឱ្យស្អាតថ្លា ហើយអាចកាត់បន្ថយបាក់តេរី និងពពួកមេរោគដែលមាននៅក្នុងទឹកបានរហូត ៩៩% ទៀតផង។ ផ្កាជាប្រភពផ្តល់នូវទឹកដមដ៏ល្អសំរាប់សត្វឃ្មុំផលិតទឹកដមរបស់វា។ ការលាយស្លឹកម្រុំទៅក្នុងដីមុនពេលដាំ អាចការពារកូនរុក្ខជាតិកុំឱ្យមានជំងឺ។ ម្យ៉ាងទៀត ប្រេងដែលចំរាញ់ចេញពីគ្រាប់ម្រុំមានតំលៃខ្ពស់ ប្រើសំរាប់ដាក់ក្នុងទឹកអប់ដើម្បីឱ្យក្លិនកាន់ជាប់បានយូរ ធ្វើជាគ្រឿងសំរាប់ការពារស្បែក ផលិតសាប៊ូ និងធ្វើជាប្រេងរំអិលបានយ៉ាងល្អប្រណីត។ នៅប្រទេសឥណ្ឌា ម្រុំត្រូវបានដាំសំរាប់យកផ្លែ ដែលសព្វថ្ងៃត្រូវបានលក់ចេញទៅទ្វីបអាស៊ី និងអឺរ៉ុប នូវផ្លែស្រស់ និងម្ហូបកំប៉ុង គ្រប់ផ្នែកទាំងអស់នៃដើមម្រុំ ត្រូវបានប្រើសំរាប់ធ្វើជាឱសថ។ គ្រូឱសថបុរាណប្រើសំបកម្រុំធ្វើជាថ្នាំកំលាំងសំរាប់ស្ត្រីទើបសំរាលកូនរួច។ ជាតិជ័រដែលចេញពីដើមម្រុំអាចប្រើប្រាស់ក្នុងការសំលាប់ស្បែក និងជ្រលក់ក្រណាត់ឱ្យរឹងល្អ។

## ៤- លក្ខណៈរុក្ខសាស្ត្រ

- **ដើមៈ** ម្រុំមានទំរង់ជាដើមឈើតូច មានកំពស់ ៥-១០ម ជួនកាលអាចដល់ ១៥ម។ ដើមម្រុំមានសាច់ឈើពណ៌ស ស្រាល ស្តោតៗ ហើយឆាប់ពុកផុយរលួយ។
- **ស្លឹកៈ** ស្លឹកម្រុំងាយដាច់ជ្រុះរបូតចេញពីទងណាស់។ ស្លឹកជាស្លឹកសមាសស្លាបខុបគ្មានរោម ស្លឹកខាងចុងបំផុតមានទំហំធំជាងគេ ហើយមានរាងពងក្រពើ ឬ រាងដូចស៊ុតដែលមានទំហំ ០,៧-២,៣ស.ម និងទទឹងពី ០,៥-១,៧ស.ម។ ចុងបន្ទះស្លឹករាងខូច។ កន្ទ្បោមស្លឹកតិច រាងដូចឆ័ត្រ ។

## ៥- ការពិពណ៌នាអំពីផ្កា ផ្លែ

- **ផ្កាៈ** ផ្កាម្រុំផុយ ងាយដាច់របូតពីទងណាស់។ ផ្កាធំមានពណ៌ស-លឿងព្រឿងៗ រាងដូចផ្កាសណ្តែក មានកេសរឈ្មោល៥។
- **ផ្លែៈ** ផ្លែមានទំហំតូច ជាផ្លែកួរ មានរាងបីជ្រុងទ្រវែង ស្រួចចុងដូចក្រញាំជើងសត្វ ដែលមានប្រវែង ១៥-៣៦ស.ម។ ពេលខ្ចីមានពណ៌បៃតង ពេលទុំមានពណ៌លឿងប្រផេះ ឬ ត្នោត ហើយអាចស្ថិតនៅលើដើមបានយូរខែមិនជ្រុះ។
- **គ្រាប់ៈ** ក្នុងមួយផ្លែមានគ្រាប់ពី ៥-២១។ ពេលនៅខ្ចីគ្រាប់មានពណ៌លឿងខ្ចី ឬ ពណ៌ពងមាន់ និង មានស្លាបពណ៌ស-ត្រួយចេកស្រាល។ ពេលទុំមានពណ៌សូកូឡា-លឿងស្រាល។




១-ផ្លែទើបទុំថ្មីៗ ២-គ្រាប់ ៣-ផ្លែដែលទុំនិងនៅលើដើមយូរខែ

គ្រាប់របស់វាមានរាងសាជីជ្រុង និងមានស្លាបពណ៌សសូកូឡាស្តើងៗ។ គ្រាប់ដែលមានសំណើម ១២,៣% មានចំនួន ៤២០០ គ្រាប់ ក្នុង១គីឡូក្រាម។

## ៦- រដូវចេញផ្កា ផ្លែ

ដើមម្រុំនឹងផ្តល់ផ្កាផ្លែ នៅពេលណាមានទឹកគ្រប់គ្រាន់ ប្រសិនបើមានភ្លៀងធ្លាក់បន្តពេញមួយឆ្នាំ នោះវានឹងហុចផលស្ទើរតែរហូត។ នៅកន្លែងដែលមានដីបែកក្រហែង ម្រុំអាចធ្វើឱ្យចេញផ្កាផ្លែបានតាមរយៈបង្កើតឱ្យមានប្រព័ន្ធប្រឡាយបង្ហូរទឹក។ ម្រុំចេញផ្កាពេញមួយឆ្នាំ និងផ្តល់នូវផ្លែមានចំនួនច្រើនទៀតផង។ ប្រភេទនេះចេញផ្កាផ្លែល្អ និងមានចំនួនច្រើនចាប់ពីឆ្នាំទី៣ បន្ទាប់ពីការដាំ។

## ៧- ការប្រមូលគ្រាប់ពូជ

ជាការចាំបាច់ត្រូវធ្វើជន្ទល់ ដើម្បីទល់មែកដែលមានផ្លែច្រើន ចៀសវាងកុំឱ្យបាក់មែក។ បើចង់បានគ្រាប់សំរាប់ចំរាញ់យកប្រេង ត្រូវហាលផ្លែទុំឱ្យស្ងួតរហូតប្រែពណ៌ទៅជាពណ៌ត្នោត។ បើផ្លែស្ថិតនៅលើដើមយូរ នោះពេលបេះគួរក្រាលកន្ទេល ឬក្រណាត់កៅស៊ូពីក្រោមដើម ព្រោះផ្លែដែលស្ងួតពេលធ្លាក់មកដីច្រើនតែប្រេះបែក។ ត្រូវបេះប្រមូលមុនពេលដែលផ្លែទាំងនោះប្រេះហើយធ្លាក់គ្រាប់មកដី។

## ៨- លទ្ធកម្មគ្រាប់ពូជ និង បញ្ហាជំងឺ

គ្រាប់ពូជត្រូវទុកដាក់ក្នុងបាវដែលមានខ្យល់ចេញចូល ហើយដាក់នៅកន្លែងស្ងួត និងមានម្លប់។ សំណើមដំបូងរបស់គ្រាប់ដែលបានបេះពេលទុំថ្មីៗមាន ៤៣% ប៉ុន្តែគ្រាប់ដែលទុំស្ងួតនៅលើដើមយូរមានសំណើមដំបូង ១២,៣%។ ដើមម្រុំមានភាពសាំទៅនឹងការបំផ្លាញនៃពពួកសត្វល្អិតស្ទើរគ្រប់ប្រភេទទាំងអស់។ ប៉ុន្តែពពួកកណ្ដៀរអាចជាបញ្ហានៅទីកន្លែងខ្លះ ហើយពពួកដង្កូវមេអំបៅអាចស៊ីស្លឹករបស់ម្រុំ។ ផ្លែម្រុំដែលនៅលើដើមយូរក្របេះប្រមូល អាចរងនូវការបំផ្លាញពីពពួកស្រមោច។

## ៩- ការសាកបណ្ដុះគ្រាប់ពូជ

មិនចាំបាច់ធ្វើប្រព្រឹត្តិកម្មគ្រាប់ទេ គឺយកគ្រាប់ទៅសាបព្រោះដោយផ្ទាល់តែម្តង។



កូនម្រុំដែលបានសាកបណ្ដុះ នៅក្នុងមន្ទីរពិសោធន៍ គំរោងគ្រាប់ពូជឈើកម្ពុជា

## ១០- ការផលិតកូនឈើ

នៅពេលកូនឈើមានអាយុ ៤-៦ខែ ទើបអាចយកទៅដាំបាន។

## ១១- ការដាំកូនឈើ

ជាទូទៅ ដើមម្រុំត្រូវបានដាំធ្វើជារបងព័ទ្ធជុំវិញផ្ទះ ឬសួនបន្លែដំណាំ ឬសំរាប់លំអ និងផ្តល់ជាម្លប់។ ម្រុំជាប្រភេទរុក្ខជាតិដុះលូតលាស់លឿន តែមិនធន់ដីជាំទឹកទេ។ ម្រុំអាចដាំដោយការកាត់មែក ដោយកូនឈើ និងដោយការសាបគ្រាប់ដោយផ្ទាល់តែម្តង។ គំលាតដាំដែលសមស្រប គឺអាស្រ័យលើគោលបំណងរបស់យើង។ បើដាំដើម្បីយកផ្លែ គួរដាំក្នុងគំលាត ៣ម x ៤ម។ បើដាំយកស្លឹកធ្វើបន្លែគួរដាំក្នុងគំលាត ០.៨ម x ១ម ដើម្បីងាយច្រូតយកស្លឹក។

## ១២- ឯកសារយោង


- នុព សុធា។ សារប្រយោជន៍នៃដើមម្រុំ។ ទស្សនាវដ្តី រុក្ខា-ប្រមាញ់ លេខ ២២ ឆមាសទី ១ ឆ្នាំ ២០០០
- ឌី ផុន ឆ្នាំ ២០០០។ វចនានុក្រមរុក្ខជាតិប្រើប្រាស់ក្នុងប្រទេសកម្ពុជា ទំព័រ ៤៤៦។
- Species Fact Sheets, 1994. Growing Multipurpose Trees on Small Farms, Page 74-75.



រដ្ឋបាលព្រៃឈើ

គំរោងគ្រាប់ពូជឈើកម្ពុជា

DANIDA

អាគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ២១៥ ០៣៤ Email: ctsp@online.com.kh




# ម្រុំ

# *Moringa aleifera* Lam